ព័ត៌មានសំខាន់ៗសម្រាប់អ្នកជួលផ្ទះដែលមានជំនួយពីក្រសួងអភិវឌ្ឍលំនៅដ្ឋាន និងទីក្រុង HUD

ស្តីពីការផ្អាកបណ្តេញចេញរបស់មជ្ឈមណ្ឌល CDC

ខែវិច្ឆិកា 2020

ប័ណ្ណផ្សព្វផ្សាយព័ត៌មាននេះ បានបង្កើតឡើងដោយការិយាល័យលំនៅដ្ឋានរដ្ឋនិងឥណ្ឌាន (PIH) នៅក្រសួងលំនៅដ្ឋាននិងការអភិវឌ្ឍទីក្រុងសហរដ្ឋអាមេរិក (HUD) ដើម្បីជួយលោកអ្នកឱ្យយល់ដឹងពីអត្ថន័យនៃការចេញបទបញ្ជារបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ CDC សម្រាប់អ្នកជួលផ្ទះដែលមានជំនួយដោយក្រសួង HUD ដែលជាអ្នកជួលផ្ទះនៅក្នុងកម្មវិធីលំនៅដ្ឋាន PIH ដូចខាងក្រោម៖ កម្មវិធីប័ណ្ណធានាជម្រើសលំនៅដ្ឋាន (HCV) កម្មវិធីលំនៅដ្ឋានរដ្ឋ និងផ្នែក 8 កម្មវិធីស្តារនីតិសម្បទាឡើងវិញដែលសមហេតុផល (Mod Rehab)។ ប្រសិនបើលោកអ្នកជាអ្នកជួលផ្ទះនៅក្នុងកម្មវិធីលំនៅដ្ឋាន PIH សូមទាក់ទងម្ចាស់ផ្ទះជួល ឬទីភ្នាក់ងារលំនៅដ្ឋានរដ្ឋ (PHA) របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីប័ណ្ណផ្សព្វផ្សាយនេះ ឬការចេញបទបញ្ជារបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ CDC។ លោកអ្នកអាចចូលមើលគេហទំព័ររបស់មជ្ឈមណ្ឌល CDC ផងដែរ តាម៖ https://www.cdc.gov/coronavirus/2019-ncov/covid-eviction-declaration.html.

តើអ្វីទៅជាការផ្អាកបណ្តេញចេញរបស់មជ្ឈមណ្ឌល CDC?

- មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (CDC) បានចេញបទបញ្ជាមួយដែលហៅថា ការបញ្ឈប់បណ្តោះអាសន្នចំពោះការបណ្តេញប្រជាពលរដ្ឋ ដើម្បីការពារការរីករាលដាលបន្ថែមទៀតពីជំងឺ COVID-19 ។ សម្រាប់អ្នកជួលផ្ទះដែលបំពេញក្នុខណ្ឌដែលមានសិទ្ធិស្របច្បាប់នោះ បទបញ្ជានេះ***បញ្ឈប់ការបណ្តេញចេញបណ្តោះអាសន្នចំពោះការមិនបង់ប្រាក់ជួលផ្ទះចាប់ពីថ្ងៃទី 4 ខែកញ្ញា ឆ្នាំ 2020 រហូតដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020 ។***

តើខ្ញុំត្រូវចាត់វិធានការអ្វីខ្លះ ដើម្បីការពារពីការបណ្តេញចេញចំពោះការមិនបង់ថ្លៃជួលផ្ទះ?

- **ជំហានទី 1៖** ប្រសិនបើលោកអ្នកស្ថិតក្នុងស្ថានភាពមិនបង់ប្រាក់ជូនដល់ម្ចាស់ផ្ទះជួល ឬទីភ្នាក់ងារ PHA របស់អ្នក ហើយលោកអ្នកមានហានិភ័យចំពោះការបណ្តេញចេញនៅចន្លោះថ្ងៃទី 4 ខែកញ្ញា ឆ្នាំ 2020 ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020 នោះលោកអ្នកត្រូវតែ**បំពេញ**លិខិតបញ្ជាក់ទាំងអស់ចំនួនប្រាំពីរនៅក្នុងសេចក្តីប្រកាសរបស់មជ្ឈមណ្ឌល CDC ដែលមាននៅទីនេះ៖
  - **ក់ណែទ្ទីជាភាសាអង់គ្លេស៖** https://www.cdc.gov/coronavirus/2019-ncov/downloads/declaration-form.pdf
  - **ក់ណែទ្ទីដែលបានបកប្រែ៖** https://www.hud.gov/program_offices/public_indian_housing/covid_19_resources/resident_declaration_form-other_languages
- **ជំហានទី 2៖** ប្រសិនបើលោកអ្នកបំពេញលិខិតបញ្ជាក់ទាំងអស់ចំនួនប្រាំពីរនៅក្នុងសេចក្តីប្រកាសរបស់មជ្ឈមណ្ឌល CDC នោះ បន្ទាប់មកលោកអ្នកត្រូវតែចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីប្រកាសនេះ។
- **ជំហានទី 3៖** ផ្តល់ច្បាប់ចម្លងនៃសេចក្តីប្រកាសដែលបានចុះហត្ថលេខា/ចុះកាលបរិច្ឆេទមួយច្បាប់ជូនទៅទីភ្នាក់ងារ PHA ឬម្ចាស់ផ្ទះជួលរបស់អ្នក។

ជំហានទី 1៖ ជាដំបូង

លោកអ្នកត្រូវតែបំពេញលិខិតបញ្ជាក់ទាំងអស់ចំនួនប្រាំពីរនៅក្នុងសេចក្តីប្រកាសរបស់មជ្ឈមណ្ឌល CDC ។ រាជាះ

1. **លោកអ្នកមិនអាចបង់ប្រាក់ថ្លៃជួលពេញលេញរបស់អ្នកបានទេ ដោយសារតែការថយចុះប្រាក់ចំណូលក្នុងគ្រួសារ ឬការចំណាយផ្នែកវេជ្ជសាស្ត្រដែលខុសប្រក្រតី។**
   - **ការណែនាំ!** សម្រាប់អ្នកចូលរួមលំនៅដ្ឋាន និងអ្នកចូលរួមប័ណ្ណធានារដ្ឋនោះ ថ្លៃជួលរបស់អ្នកនឹងត្រូវកែតម្រូ**ក្រប់ពេលវេលា** ដើម្បីបង្ហាញពីការថយចុះប្រាក់ចំណូល ប្រសិនបើលោកអ្នករាយការណ៍ពីការផ្លាស់ប្តូរប្រាក់ចំណូលជូនទៅទីភ្នាក់ងារ PHA របស់អ្នក។ សូមគិតពិចារណាទាក់ទងទីភ្នាក់ងារ PHA របស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីពិនិត្យឡើងវិញនូវប្រាក់ចំណូលបច្ចុប្បន្នរបស់អ្នក និងកែសម្រួលថ្លៃជួលរបស់អ្នក ដើម្បីបង្ហាញពីការផ្លាស់ប្តូរ។
2. **លោកអ្នកកំពុងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីទូទាត់ប្រាក់មួយផ្នែកៗទាន់ពេលវេលា ដែលជិតដល់ការទូទាត់ប្រាក់ពេញលេញតាមស្ថានភាពដែលអនុញ្ញាត។**
3. **លោកអ្នកបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីទទួលបានរាល់ជំនួយដែលមានពីរដ្ឋាភិបាល។**
   - **ការណែនាំ!** លោកអ្នកអាចគិតពិចារណាក្នុងការចូលរួមនាពេលបច្ចុប្បន្នរបស់អ្នកនៅក្នុងកម្មវិធីជំនួយថ្លៃជួលផ្ទះ ដើម្បីកំណត់ថាតើលោកអ្នកបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីទទួលបានជំនួយពីរដ្ឋាភិបាលឬទេ។ អ្នកចូលរួមលំនៅដ្ឋាន និងអ្នកចូលរួមប័ណ្ណធានារដ្ឋ អាចនឹងគិតពិចារណាផងដែរ ប្រសិនបើពួកគេបានស្នើសុំទីភ្នាក់ងារ PHA ឱ្យពិនិត្យមើលប្រាក់ចំណូលបច្ចុប្បន្នរបស់ពួកគេ និងកែសម្រួលថ្លៃជួល ដើម្បីបង្ហាញពីការផ្លាស់ប្តូរប្រាក់ចំណូល។
4. **លោកអ្នកបំពេញលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម៖ (1) លោកអ្នករំពឹងថានឹងរកប្រាក់បានតិចជាង 99,000 ដុល្លារក្នុងឆ្នាំ 2020 (ឬ 198,000 ដុល្លារ ប្រសិនបើដាក់ឯកសាររួមគ្នា) ឬ (2) លោកអ្នកមិនចាំបាច់ត្រូវរាយការណ៍អំពីប្រាក់ចំណូលណាមួយជូនទៅ IRS ឬ (3) លោកអ្នកបានទទួលការត្រួតពិនិត្យការលើកទឹកចិត្តពីច្បាប់ (CARES Act)។**
   - **ការណែនាំ!** ការទូទាត់ប្រាក់លើកទឹកចិត្តចំនួន 1,200 ដុល្លារ មិនរាប់បញ្ចូលក្នុងការគណនាប្រាក់ចំណូលរបស់អ្នកទេ។ ប្រសិនបើលោកអ្នកមិនបានទទួលការទូទាត់ប្រាក់លើកទឹកចិត្តទេ សូមចូលមើលគេហទំព័រនេះ ដើម្បីពិនិត្យមើលស្ថានភាពនៃការទូទាត់ប្រាក់របស់អ្នក និងបំពេញសំណុំបែបបទងាយៗ៖ https://www.irs.gov/coronavirus/get-my-payment

5. **ក្យសិនបើនោរអនរក្ជូបាននរបនណា ញនេញ នោរអនរទំន្ទ្ធ្ធ្ធ

6. **នោះអនុវយល់ថានោះអនុវទទួលខុសក្តវិន ៖ការប់ុនងលជួលដ្ឋើនបានប់ុក្បារ់ នោះអនុវអាក្ដេវបានវិតនងលឈ្ជនលេ៉ន ៖ នងលជួលដ្ឋើនបានប់ុក្បារ់ ន្ងហើយនោះអនុវក្ដ្ជ្ជ្ជ

ការណែនាំអំពីការប្រាស្រ័យទាក់ទងជាមួយម្ចាស់ផ្ទះជួលឬទីភ្នាក់ងារ PHA របស់អ្នក៖

ប្រសិនបើលោកអ្នកកំពុងព្យាយាមបង់ប្រាក់ថ្លៃជួលផ្ទះ ឬមិនអាចបង់ប្រាក់បានទៀតទេ សូមទាក់ទងម្ចាស់ផ្ទះជួលរបស់អ្នកភ្លាមៗ ដើម្បីពិភាក្សាអំពីជម្រើសរបស់អ្នក។ នៅអំឡុងពេលមានបញ្ហាហិរញ្ញវត្ថុ ម្ចាស់ផ្ទះជួលរបស់អ្នកអាចមានបញ្ហាប្រឈមផងដែរ។ សូមព្យាយាមប្រាស្រ័យទាក់ទងជាមួយពួកគេឱ្យបានច្បាស់ និងដោយស្ងប់ចិត្ត។
ហើយនេះជាគន្លឹះខ្លះៗដើម្បីជួយណែនាំលោកអ្នកតាមរយៈការសន្ទនាជាមួយម្ចាស់ផ្ទះជួលរបស់អ្នក៖

- និយាយដោយស្មោះត្រង់អំពីស្ថានភាពរបស់អ្នក។ ប្រសិនបើលោកអ្នកទទួលរងផលប៉ះពាល់ដោយសារ COVID-19 ឬការលំបាកផ្សេងៗ សូមចែករំលែកពីបញ្ហាដែលធ្វើឱ្យប្រាក់ចំណូលរបស់អ្នករងផលប៉ះពាល់។ <u>អ្នកចូលរួមលំនៅដ្ឋានរដ្ឋ និងអ្នកចូលរួមប័ណ្ណធានា</u> គួរទាក់ទងទីភ្នាក់ងារ PHA របស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីពិនិត្យឡើងវិញនូវប្រាក់ចំណូលបច្ចុប្បន្នរបស់អ្នក និងកែសម្រួលការបង់ប្រាក់ថ្លៃជួលរបស់អ្នក។
- សូមគិតពិចារណាលើការលើកមកនិយាយអំពីធនធាននិងជម្រើសជំនួយណាមួយដែលលោកអ្នកបានរកឃើញ។
- ពន្យល់ពីរបៀបដែលគ្រួសាររបស់អ្នកនឹងទទួលរងផលប៉ះពាល់ដោយសារការបាត់បង់លំនៅដ្ឋាន។
- សាកសួរអំពីការរៀបចំទូទាត់ប្រាក់។
- រក្សាការសន្ទនាតាមអ៊ីម៉ែលនិងអត្ថបទណាមួយ និងកត់ចំណាំនៅពេលលោកអ្នកបាននិយាយតាមទូរសព្ទឬជួបដោយផ្ទាល់។

[1] បានអនុម័តនៅផ្នែក 4024 នៃច្បាប់ស្តីពីជំនួយសង្គ្រោះបន្ទាន់ ការជួយដោះបន្ទុក និងការធានាផ្នែកសេដ្ឋកិច្ចដោយសារវីរុសកូរ៉ូណា, ច្បាប់ 2020 “CARES Act” (ច្បាប់សាធារណៈ 116-136)។